ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០២...សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៥

**សារាចរណែនាំ**

**ស្តីពី**

**ការអនុវត្តភារកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម**

អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ខែកុម្ភៈឆ្នាំ១៩៩៧ និងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស លេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យមានសង្គតិភាពក្នុងការអនុវត្តភារកិច្ចពន្ធលើប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភដូចខាងក្រោម ដែលនិយោជិត កម្មករ កម្មការិនី នៃរោងចក្រនានា ទទួលបានពីការបំពេញការងារ មិនត្រូវបានគិតបញ្ចូលក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

១. សោហ៊ុយធ្វើដំណើរពីទីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការឬរោងចក្រ និងពីទីកន្លែងធ្វើការឬរោងចក្រទៅកន្លែងស្នាក់នៅ និងការឧបត្ថម្ភថ្លៃស្នាក់នៅឬការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណរោងចក្រ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ។

២. ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យនិយោជិត កម្មករ កម្មការិនី ទាំងអស់ដោយគ្មានបែងចែកតាមតួនាទីឬមុខងារ រួមទាំងប្រាក់ថ្លៃបាយបន្ថែមម៉ោង។

៣. មូលនិធិបេឡាសន្តិសុខសង្គម ឬមូលនិធិសុខមាលភាពសង្គមក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់។

៤. ប្រាក់ធានារ៉ាប់រងសុខភាព ឬបុព្វលាភធានារ៉ាប់រងអាយុជីវិតឬសុខភាពដែលផ្តល់ឱ្យដល់ និយោជិត កម្មករ កម្មការិនី គ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ។

៥. ប្រាក់ឧបត្ថម្ភទារក ឬចំណាយទារកដ្ឋាន ដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ការងារ។

៦. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

អគ្គនាយកដ្ឋានពន្ធដារ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវសហការអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ឯកសារ កាលប្បវត្តិ

អគារលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com